# កំលាំងចិត្តវិជ្ជមាន និង អវិជ្ជមានរបស់អ្នកគាំពារសង្គម

ការងារជួយអតិថិជនធ្វើអោយអ្នកទាក់ទងដោយផ្ទាល់ទៅនឹងជីវិតរបស់ពួកគាត់។ ប្រហែលអ្នកមានបទពិសោធន៍ខ្លះៗ ដែលបង្ហាញថា ក្តីមេត្តាករុណារបស់អ្នកចំពោះអតិថិជននោះអាចប៉ះពាល់ដល់អ្នកវិញទាំងវិជ្ជមានទាំងអវិជ្ជមាន។ យើងចង់សួរសំនួរខ្លះៗទាក់ទងនឹងបទពិសោធន៍របស់អ្នកទាំងវិជ្ជមានទាំងអវិជ្ជមានក្នុងការងារសង្គមកិច្ច។ សូមគិតពិចារណាអំពីសំណួរដូចតទៅអំពីខ្លួនអ្នក និង ស្ថានភាពការងាររបស់អ្នកពេលបច្ចុប្បន្ននេះ។ សូមជ្រើសរើសលេខ ដែលបង្ហាញពីភាពញឹកញាប់នៃរឿងទាំងអស់នោះដែលកើតឡើងក្នុងជីវិតរបស់អ្នកកំឡុង៣០ថ្ងៃមុន ដោយស្មោះត្រង់។

| | | |
|---|---|---|
| ១ = មិនដែល | ៣ = ជួនកាល | ៥ = ញឹកញាប់មែនទែន |
| ២ = ដោយកំរ | ៤ = ញឹកញាប់ | |

--- ១ ខ្ញុំសប្បាយចិត្ត។

--- ២ ខ្ញុំមានអតិថិជនច្រើនជាងម្នាក់ ដែលធ្វើអោយខ្ញុំខ្វាយខ្វល់។

--- ៣ ខ្ញុំពេញចិត្តពីព្រោះខ្ញុំអាចជួយអតិថិជនបាន។

--- ៤ ខ្ញុំយល់ចិត្តអ្នកដទៃ។

--- ៥ ខ្ញុំលោត ឬ ភ្ញាក់ផ្អើល ពេលលឺសំលេងលាន់លឺខ្លាំងៗ ម្តងៗ។

--- ៦ ការជួយអតិថិជនធ្វើអោយខ្ញុំមានកម្លាំង។

--- ៧ សំរាប់ខ្ញុំ គឺ ពិបាកក្នុងការបែងចែកជីវិតផ្ទាល់ខ្លួន និង ការងារខ្ញុំ។

--- ៨ ខ្ញុំគេងមិនលក់ ដោយសារខ្ញុំគិតច្រើនពីការប៉ះទង្គិចផ្លូវចិត្តរបស់អតិថិជន។

--- ៩ ខ្ញុំគិតថា ប្រហែលជំងឺបាក់ស្បាតរបស់អតិថិជនឆ្លងមកខ្ញុំ ហើយ ធ្វើអោយខ្ញុំធ្វើការងារមិនសូវល្អ។

--- ១០ ខ្ញុំមានអារម្មណ៍ដូចជាការងារខ្ញុំចាប់ខ្ញុំដាក់ក្នុងអង្គប់។

--- ១១ ខ្ញុំមានអារម្មណ៍ថា រឿងអាក្រក់ប្រហែលអាចកើតឡើងដោយចៃដន្យ ដោយសារសំពាធការងាររបស់ខ្ញុំ។

--- ១២ ខ្ញុំចូលចិត្តការងារខ្ញុំ។

--- ១៣ ខ្ញុំធុញថប់ដោយសារការប៉ះទង្គិចផ្លូវចិត្តរបស់អតិថិជន ។

--- ១៤ ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំមានបទពិសោធន៍ដូចអតិថិជន ដែលមានការប៉ះទង្គិចផ្លូវចិត្ត ។

--- ១៥ ខ្ញុំមានជំនឿដែលទ្រទ្រង់ខ្ញុំ ។

--- ១៦ ខ្ញុំសប្បាយចិត្តត្រង់ថាខ្ញុំអាចរៀនឆាប់ចេះនូវជំនាញផ្សេងៗ និង ពិធីការទាំងចាស់
ទាំងថ្មីក្នុងការងារសង្គមកិច្ច ។

--- ១៧ ខ្ញុំពេញចិត្តនឹងខ្លួនឯង ។

--- ១៨ ការងារខ្ញុំធ្វើអោយខ្ញុំពេញចិត្ត ។

--- ១៩ ការងារខ្ញុំធ្វើអោយខ្ញុំអស់កម្លាំង ។

--- ២០ ខ្ញុំមានអារម្មណ៍សុខកាយសប្បាយចិត្តចំពោះអតិថិជនខ្ញុំ និង របៀបដែលខ្ញុំជួយពួកគាត់ ។

--- ២១ ខ្ញុំមានអារម្មណ៍ថាការងារខ្ញុំ ឬ ចំនួនករណីខ្ញុំមានច្រើនលើសលប់ ។

--- ២២ ខ្ញុំជឿថាខ្ញុំអាចកែប្រែជីវិតរបស់អតិថិជន និង សង្គមខ្មែរ ។

--- ២៣ ខ្ញុំជៀសវាងធ្វើសកម្មភាពខ្លះ ហើយគេចពីស្ថានភាពខ្លះ ពីព្រោះវារំលឹកខ្ញុំពីបទពិសោធន៍
ដែលគួរអោយខ្លាច របស់អតិថិជន ។

--- ២៤ ខ្ញុំពេញចិត្តពីអ្វីដែលខ្ញុំធ្វើដើម្បីជួយអតិថិជន ។

--- ២៥ ការងារខ្ញុំធ្វើអោយខ្ញុំកើតគំនិត ដែលស្មុគស្មាញបញ្ជ្រៀតចូលក្នុងអារម្មណ៍ខ្ញុំ ។

--- ២៦ ខ្ញុំមានអារម្មណ៍ថា ប្រព័ន្ធការងារនៅ BGH ធ្វើអោយខ្ញុំទៅមុខមិនរួច ។

--- ២៧ ខ្ញុំមានគំនិតថាខ្ញុំជោគជ័យ ។

--- ២៨ ខ្ញុំនឹកមិនឃើញផ្នែកសំខាន់ៗក្នុងការងារខ្ញុំ ដែលទាក់ទងនឹងអតិថិជន
ដែលមានការប៉ះទង្គិចផ្លូវចិត្ត ។

--- ២៩ ខ្ញុំជាមនុស្សឆាប់ទន់ចិត្ត ។

--- ៣០ ខ្ញុំសប្បាយចិត្ត ដែលខ្ញុំជ្រើសរើសការងារត្រូវ ក្នុងការធ្វើជាបុគ្គលិកសង្គមកិច្ច ។